# តើលោកអ្នកអាចធ្វើអ្វីខ្លះ ដើម្បីទប់ស្កាត់ស្ថានភាពគ្រោះថ្នាក់ នៃការប្រើអ៊ិនធ័រណិតរបស់កូនលោកអ្នក?

- និយាយជាមួយកូនរបស់លោកអ្នកអំពីគ្រោះថ្នាក់ដែលអាចកើតមានឡើងនៃការប្រើអ៊ិនធ័រណិត។
- ចំណាយពេលប្រើអ៊ិនធ័រណិតជាមួយកូនរបស់លោកអ្នក។ ឲ្យកូនបង្រៀនលោកអ្នកអំពី វ៉ិបសៃដែលពួកគេចូលចិត្ត។
- ទុកកុំព្យូទ័រនៅក្នុងបន្ទប់ដែលប្រើរួមគ្នានៅក្នុងផ្ទះ កុំទុកនៅក្នុងបន្ទប់គេងរបស់កូនលោកអ្នក។
- ប្រើ កម្មវិធីគ្រប់គ្រងរបស់មាតាបិតា (parental controls) ដែលក្រុមហ៊ុនអ៊ិនធ័រណិតផ្តល់ឲ្យ និង/ឬ កម្មវិធីទប់ស្កាត់អ្វីដែលមិនល្អ (blocking software)។ ជាពិសេស បន្ទប់សន្ទនាតាមអ៊ិនធ័រណិត (chat rooms) ត្រូវមានការតាមមើលឲ្យបានដិតដល់។ ក្នុងខណដែលមាតាបិតាប្រើកម្មវិធីទប់ស្កាត់ទាំងនេះ លោកអ្នកមិនត្រូវពឹងផ្អែកទៅលើកម្មវិធីទាំងអស់នោះទាំងស្រុងទេ។
- ត្រូវរក្សាសិទ្ធិដែលអាចមើលអ៊ិនធ័រណិតដែលកូនរបស់លោកអ្នកប្រើ ហើយម្តងម្កាលត្រូវពិនិត្យមើលអ៊ីមែលរបស់កូនលោកអ្នក។ ត្រូវដឹងថា គេក៏អាចទាក់ទងកូនរបស់លោកអ្នកតាមប៉ុស្តិ៍សំបុត្របានដែរ។ ត្រូវប្រាប់ឲ្យកូនដឹងមុន អំពីការចូលមើលអ៊ិនធ័រណិតរបស់ពួកគេ ហើយប្រាប់កូនពីមូលហេតុនៃការធ្វើបែបនេះ។
- បង្រៀនកូនពីការទទួលខុសត្រូវនៃការប្រើព័ត៌មានតាមអ៊ិនធ័រណិត។
- ស្វែងយល់អំពីវិធីការពារការប្រើកុំព្យូទ័រនៅ សាលា នៅបណ្ណាល័យរដ្ឋ និងនៅផ្ទះមិត្តភ័ក្តរបស់កូនលោកអ្នក។ កន្លែងទាំងនេះ នៅក្រៅការត្រួតត្រារបស់លោកអ្នក ដែលកូនលោកអ្នកអាចជួបប្រទះនឹងជនអាក្រក់តាមអ៊ិនធ័រណិត។
- ត្រូវដឹងថា ទោះជាកូនរបស់លោកអ្នកស្ម័គ្រចិត្តចូលរួមនឹងអំពើកេងចំណេញផ្នែកកាមគុណ  វាមិនមែនជាកំហុសរបស់ពួកគេទេ កូនលោកអ្នកគឺជាជនរងគ្រោះ។ ជនប្រព្រឹត្តបទល្មើស ជាអ្នកទទួលខុសត្រូវនូវអ្វីៗទាំងអស់ដែលគេធ្វើ។
- ណែនាំកូន៖
    - កុំឲ្យណាត់ជួបផ្ទាល់ ជាមួយអ្នកណាម្នាក់ដែលគេបានជួបតាមអ៊ិនធ័រណិត។
    - កុំឲ្យបង្ហោះរូបថតរបស់ខ្លួនតាមអ៊ិនធ័រណិត ឬ វ៉ិបសៃ ទៅអ្នកដែលគេមិនស្គាល់។
    - កុំផ្តល់ព័ត៌មានផ្ទាល់ខ្លួនឲ្យគេស្គាល់ ដូចជា ឈ្មោះ អាស័យដ្ឋាន ឈ្មោះសាលា ឬ លេខទូរស័ព្ទ។
    - កុំឲ្យកូនចម្លងយករូបថតពីប្រភពដែលគេមិនស្គាល់ ដោយសារវាអាចជារូបអាសអាភាស។
    - កុំឲ្យឆ្លើយតបទៅនឹង សារតាមក្នុងអ៊ិនធ័រណិត ដែលមានភាព ថោកទាប ជម្លោះ ឬ យាយី។
    - ថាដំណឹងអ្វីៗដែលគេប្រាប់តាមអ៊ិនធ័រណិត អាចពិត ឬ មិនពិត។